កង្ហែច

កង្ហែច (ខ្មែរយើងច្រើនហៅថា "អង្ហែច" ទៅវិញ) ជាឧបករណ៍តន្ត្រីមួយប្រភេទដែលគេឃើញមាននៅក្នុងតំបន់ផ្សេងៗនៃពិភពលោក រួមទាំងតំបន់អាស៊ីអគ្នេយ៍ មានប្រទេសកម្ពុជាផងដែរៗ[១][២]

យើងគប្បីហៅឧបករណ៍តន្ត្រីនេះថា "កង្ហែច" ព្រោះពាក្យ "កង្ហែច" មានន័យថា "ស្រែករកគ្នា" ដែលអ្នកលេងកង្ហែចប្រើដើម្បីទាក់ទងឬបញ្ជូនសារទៅគ្នាៗ[៣] កង្ហែច ធ្វើពីឫស្សីឬដៃកមានអណ្តាតដូចស្នែង ហើយមានរាងត្រង់ឬខាងចុងសងខាងដូចទូកៗ កង្ហែច មានបណ្តោយប្រវែងប្រមាណមួយចំអាម និងទទឹងប្រមាណប៉ុនម្រាមដៃ។ បើធ្វើពីឫស្សី គេត្រូវយកឫស្សីឲ្យមានជាប់ថ្នាំងម្ខាង បិតឲ្យជបក្បាលបន្តិចៗ បន្ទាប់ពីថ្នាំងមក គេត្រូវបិតឲ្យស្តើងរៀវទៅខាងចុង ហើយពុះចុងឫស្សីនោះជាបីភាគ ដោយទុកភាគកណ្តាលឲ្យលយវែងជាងគេ ហើយធ្វើឲ្យត្រមោងចុងបន្តិចដើម្បីធ្វើអណ្តាត។ គេបិតអណ្តាតឲ្យស្តើង ដើម្បីឲ្យផ្ទុំទៅឮសូររលាស់ល្អ។ បើធ្វើពីដៃក គេក៏ធ្វើប្រហាក់ប្រហែលគ្នានឹងឫស្សីដែរ ខុសតែវាងវៃបន្តិចៗ[៤]

របៀងលេង

ពេលលេង គេយកដៃឆ្វេងកាន់កង្ហែចដាក់ផ្នប់នឹងមាត់ យកដៃស្តាំផ្ចាត់ចុងអណ្តាតកង្ហែច ដោយអ្នកលេងបញ្ចេញខ្យល់ធ្វើបទតាមមាត់ខ្លួនឯង។

របៀបប្រើប្រាស់

នៅកម្ពុជាយើង ឧបករណ៍កង្ហែចត្រូវបានប្រើដោយអ្នកឃ្វាលគោក្របី ចាំស្រែចម្ការ ឬសម្រាប់ទំនាក់ទំនងផ្ញើសាររវាងបុរស និងស្ត្រី។ គេសម្តែងឧបករណ៍នេះទោល ឬកំដរអ្នកច្រៀង។ គេមិនឃើញមានប្រើនៅក្នុងវង់ភ្លេងឡើយ។

តាមការស្រាវជ្រាវរបស់យើង យើងឃើញថាអ្នកដែលចេះលេងកង្ហែចមានចំនួនតិចណាស់នៅកម្ពុជាយើងសព្វថ្ងៃ ទាំងនៅទីក្រុង និងជនបទ។ ដោយសារកត្តាខាងលើនេះ

---

[១] សំ សំអាង ២០០២: ទំព័រ៣៩

[២] ជួន ណាត ១៩៦: ទំព័រ១៥៩

[៣] ជួន ណាត ១៩៦៧: ទំព័រ២៨

[៤] ពេជ សល់ ១៩៧០: ទំព័រ២៣

និងមិនមានតម្រូវការឲ្យឧបករណ៍កង្ហែចប្រើប្រាស់នៅក្នុងវង់តន្ត្រី ជាពិសេសកំដរពិធីដែលផ្សាភ្ជាប់នឹងជីវិតរបស់ប្រជាជន ព្រមទាំងមធ្យោបាយទំនាក់ទំនងបច្ចេកវិទ្យាទំនើបសម្បូណ៌បែបនាពេលបច្ចុប្បន្នផង កង្ហែចស្ទើរតែបាត់បង់លែងឃើញគេសម្តែង។

ពិធីបុណ្យទាន ប្រពៃណី និងទំនៀមទម្លាប់ដែលតម្រូវឲ្យមានតន្ត្រីកំដរ គឺជាកត្តាមួយដ៏សំខាន់ជួយឲ្យឧបករណ៍រស់។ លើសពីនេះទៅទៀត ការសិក្សារៀនសូត្រ និងយល់ដឹងពីវប្បធម៌ជាតិ ក៏ជាកត្តាសំខាន់ដើម្បីអ្នកបន្តវេនគោរពស្រឡាញ់ និងថែរក្សាសម្បត្តិវប្បធម៌ជាតិបន្តទៅអនាគត។

ឧបករណ៍កង្ហែចធ្វើពីឈើ និងដែក

ឯកសារយោង

ជួន ណាត

១៩៦៧. "វចនានុក្រមខ្មែរ". ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ពេជ សល់

១៩៧០. "អំពីលំនាំសង្ខេបនៃភ្លេងខ្មែរ"ឦ ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Sam, Sam-Ang.

2002. "*Musical Instruments of Cambodia*. Osaka%: National Museum of Ethnology.